## តើខ្ញុំទៅរកព័ត៌មានបន្ថែមនៅកន្លែងណា?

ចូរទាក់ទងការិយាល័យទំនាក់ទំនងការរស់នៅសហគមន៍ក្នុងតំបន់របស់អ្នក/ ការិយាល័យទីភ្នាក់ងារប្រចាំតំបន់លើវ័យចំណាស់ ៖ អ្នកអាចស្វែងទីតាំង និងលេខទូរស័ព្ទក្នុងតំបន់នៅ www.waclc.org ក្រោមផ្នែកទំនាក់ទំនង ឬហៅទូរស័ព្ទឥតគិតថ្លៃតាមលេខ 1-855-567-0252។

ឬចូលមើល www.dshs.wa.gov/altsa/home-and-community-services/caregiver-resources សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីទាំងនេះ និងធនធានអ្នកផ្តល់ការថែទាំផ្សេងទៀត។

*សេវាកម្ម និងការគាំទ្រទាន់ពេលវេលា ដែលមានកំណត់សម្រាប់បុគ្គលម្នាក់ៗ ឬអ្នកផ្តល់ការថែទាំរបស់ពួកគេ ជួយប្រជាជនបន្តរស់នៅឯករាជ្យ ជីវិតមានសុខភាពល្អក្នុងផ្ទះរបស់ពួកគេ។*

DSHS 22-1739 CA (Rev. 7/18) Cambodian

# ការថែទាំជំនួស និងការគាំទ្រតាមតម្រូវការ Medicaid សម្រាប់មនុស្សចាស់

*អ្នកផ្តល់ការថែទាំមិនគិតកម្រៃគឺជាឆ្អឹងខ្នងនៃសេវាកម្ម និងការគាំទ្ររយៈពេលវែងរបស់យើង។ សេវាកម្មទាំងនេះគឺត្រូវបានរចនាឡើងដើម្បីជួយអ្នកផ្តល់ការថែទាំមិនគិតកម្រៃក្នុងការទទួលការគាំទ្រដែលចាំបាច់ដើម្បីបន្តផ្តល់ការថែទាំគុណភាពខ្ពស់ និងដើម្បីផ្តោតលើសុខភាព និងសុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគេ។*



Washington State
Department of Social & Health Services
*Transforming lives*

រដ្ឋវ៉ាស៊ីនតោនកំពុងផ្តល់ពីរវិធីបន្ថែមដើម្បីគាំទ្រមនុស្សចាស់ដែលត្រូវការជំនួយរស់នៅក្នុងផ្ទះ។ កម្មវិធីទាំងនេះដែលបានរៀបរាប់ខាងក្រោម គាំទ្រអ្នកផ្តល់ការថែទាំងគ្រួសារដែលគិតកម្រៃរបស់ពួកគេ ឬគាំទ្របុគ្គលម្នាក់ៗដែលបច្ចុប្បន្នមិនមានអ្នកផ្តល់ការថែទាំម្នាក់ដែលមិនគិតកម្រៃ។ ការិយាល័យទំនាក់ទំនងការរស់នៅសហគមន៍ក្នុងតំបន់របស់អ្នក ឬការិយាល័យទីភ្នាក់ងារតំបន់វ័យចំណាស់ប្រចាំតំបន់ អាចផ្តល់ព័ត៌មានបន្ថែម ឬអ្នកអាចស្វែងរកព័ត៌មានលើបណ្តាញ។



## តើកម្មវិធីទាំងនេះផ្តល់អ្វីខ្លះ?

កម្មវិធីទាំងពីរផ្តល់ជួរទូលាយមួយនៃសេវាកម្ម និងការគាំទ្រដែលអ្នកអាចមានសិទ្ធិទទួល រួមមាន ៖

- កិច្ចការរៀបចំផ្ទះ និងកិច្ចការទៀតៗ
- ក្រុមគាំទ្រ និងការប្រឹក្សាយោបល់
- គ្រឿងបរិក្ខារ ឬឧបករណ៍ផ្គត់ផ្គង់វេជ្ជសាស្ត្រឯកទេស
- ជម្រើសថែទាំនៅពេលសម្រាក
- ឱកាសបណ្តុះបណ្តាល
- សុខភាពពេលថ្ងៃមនុស្សពេញវ័យ ឬការថែទាំពេលថ្ងៃមនុស្សពេញវ័យ
- ព័ត៌មានអំពីការផ្តល់ការថែទាំ ធនធាននានានៅក្នុងសហគមន៍របស់អ្នក សេវាកម្មដែលអាចរកបាន និងច្រើនទៀត។

ក្រោម**ការគាំទ្រតាមតម្រូវការសម្រាប់មនុស្សចាស់** សេវាជំនួយផ្ទាល់ខ្លួន (រួមទាំងការថែទាំផ្ទាល់ខ្លួន និងគណៈប្រតិភូគិលានុបដ្ឋាយិកា) គឺជាជម្រើសបន្ថែមមួយ ជំនួសឱ្យពេលសម្រាក សម្រាប់មនុស្សពេញវ័យដែលមិនមានអ្នកផ្តល់ការថែទាំ គឺមានអាយុ 55 ឬចាស់ជាងនេះ និងបំពេញបានតាមតម្រូវការខាងមុខងារ និងខាងហិរញ្ញវត្ថុ។

| នរណា | ឈ្មោះ កម្មវិធី | តម្រូវការ អាយុ | តម្រូវការ Medicaid | តម្រូវការ ដទៃ | កម្រិត អត្ថប្រយោជន៍ |
|---|---|---|---|---|---|
| **អ្នកផ្តល់ការថែទាំ** | ការថែទាំជំនួស Medicaid (MAC) | អ្នកទទួលការថែទាំត្រូវតែមានអាយុ 55+ ហើយអ្នកផ្តល់ការថែទាំត្រូវតែមានអាយុ 18+។ | តម្រូវឱ្យអ្នកទទួលការថែទាំបច្ចុប្បន្ននៅ Apple Health (Medicaid)។ | អ្នកទទួលការថែទាំត្រូវតែជួយជាមួយសកម្មភាពមួយចំនួននៃការរស់នៅប្រចាំថ្ងៃ ដូចជាការងូតទឹក ការដើរ ការលេបថ្នាំ ការផ្ទេរ។ល។ | ដោយផ្អែកលើស្ថានភាពរបស់អ្នក អ្នកអាចទទួលកម្រិតខុសគ្នាមួយក្នុងចំណោមបីនៃសេវាកម្ម និងការគាំទ្រ។ |
| **អ្នកផ្តល់ការថែទាំ ឬមនុស្សចាស់ដោយគ្មានអ្នកផ្តល់ការថែទាំ** | ការគាំទ្រតាមតម្រូវការសម្រាប់មនុស្សចាស់ (TSOA) | អ្នកទទួលការថែទាំត្រូវតែមានអាយុ 55+ ហើយអ្នកផ្តល់ការថែទាំត្រូវតែមានអាយុ 18+។ | ភាពមានសិទ្ធិទទួលបាន Medicaid គឺមិនមែនជាតម្រូវការឡើយ។ ចំណូល និងធនធានរបស់អ្នកអាចលើសពីចំនួន Medicaid។ បុគ្គលិកនឹងជួយអ្នកកំណត់ភាពមានសិទ្ធិទទួលបានហិរញ្ញវត្ថុរបស់អ្នក។ | អ្នកទទួលការថែទាំត្រូវតែជួយជាមួយសកម្មភាពមួយចំនួននៃការរស់នៅប្រចាំថ្ងៃ ដូចជាការងូតទឹក ការដើរ ការលេបថ្នាំ ការផ្ទេរ។ល។ | ដោយផ្អែកលើស្ថានភាពរបស់អ្នក អ្នកអាចទទួលកម្រិតខុសគ្នាមួយក្នុងចំណោមបីនៃសេវាកម្ម និងការគាំទ្រ។ |